ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ......០៦៨.........អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាត របស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- បានឃើញប្រកាសលេខ ០០៣/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម
- យោងតាមការចាំបាច់របស់និយ័តករមូលបត្រកម្ពុជា

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១** .-

ប្រកាសនេះមានគោលបំណងកំណត់ពីកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងបទប្បញ្ញត្តិដទៃទៀតក្នុងវិស័យមូលបត្រ ដើម្បីត្រួតពិនិត្យ និងតាមដាននូវការបំពេញកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

**ប្រការ២** .-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) និងបុគ្គលពាក់ព័ន្ធក្នុងប្រតិបត្តិការអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

**ប្រការ៣** .-

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងមាននៅក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម។

**បុគ្គលិកជាន់ខ្ពស់** សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុនដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងអភិបាល។

**បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ** សំដៅដល់អភិបាល នាយកប្រតិបត្តិ សមាជិកគណៈកម្មាធិការវិនិយោគ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ ដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពី **ន.ម.ក.**។

## ជំពូកទី ២

## កាតព្វកិច្ចផ្តល់របាយការណ៍

**ប្រការ៤** .-

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវផ្តល់ជូន **ន.ម.ក.** នូវរបាយការណ៍ប្រចាំខែដូចខាងក្រោម៖

១- របាយការណ៍តុល្យការសាកល្បងសង្ខេប។

២- របាយការណ៍សន្ទនីយភាព។

៣- របាយការណ៍ស្តីពីស្ថានភាពអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

**ប្រការ៥** ._

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវផ្តល់ជូន **ន.ម.ក.** នូវរបាយការណ៍ប្រចាំឆមាសដូចខាងក្រោម៖

១- របាយការណ៍ហិរញ្ញវត្ថុផ្ទៃក្នុងរបស់ក្រុមហ៊ុនដែលបានរៀបចំអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់-ព័ន្ធនឹងគណនេយ្យ និងសវនកម្ម។

២- របាយការណ៍អំពីការជួញដូរមូលបត្រ ឯកតាមូលនិធិ ឬឧបករណ៍ហិរញ្ញវត្ថុប្រហាក់ប្រហែលផ្សេងទៀតរបស់ក្រុមហ៊ុន អភិបាល សហកម្មសិទ្ធិករ និងនិយោជិតរបស់ក្រុមហ៊ុន។

៣- របាយការណ៍ស្តីពីការត្រួតពិនិត្យផ្ទៃក្នុង។

៤- របាយការណ៍ស្តីពីការវាយតម្លៃរបស់បុគ្គលិកជំនាញផ្នែកច្បាប់លើអនុលោមភាពតាមច្បាប់របស់ក្រុមហ៊ុន។

៥- របាយការណ៍ស្តីពីការគ្រប់គ្រងហានិភ័យ។

៦- របាយការណ៍ស្តីពីសវនកម្មផ្ទៃក្នុង។

៧- របាយការណ៍អំពីភាគហ៊ុនិក ក្រុមប្រឹក្សាភិបាល សមាសភាពគណៈកម្មាធិការវិនិយោគ បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ ភ្នាក់ងារគ្រប់គ្រងមូលនិធិ និងនិយោជិត។

៨- របាយការណ៍ស្តីពីការដោះស្រាយវិវាទ និងពាក្យបណ្តឹង។

**ប្រការ៦** ._

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវផ្តល់ជូន **ន.ម.ក.** នូវរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

១- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវបានធ្វើសវនកម្មរួចដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក.**។

២- របាយការណ៍វាយតម្លៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ប្រតិបត្តិការអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ដែលត្រូវបានធ្វើការវាយតម្លៃដោយក្រុមហ៊ុនវាយតម្លៃបច្ចេកវិទ្យាព័ត៌មាននៅក្នុងវិស័យមូលបត្រដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.**។

៣- របាយការណ៍អំពីសមិទ្ធផល និងបញ្ហាប្រឈម ដែលអនុវត្តតាមផែនការអាជីវកម្មដែលបានដាក់តម្កល់នៅ **ន.ម.ក.**។

៤- អង្គការលេខបច្ចុប្បន្នរបស់ក្រុមហ៊ុន។

៥- រចនាសម្ព័ន្ធបច្ចុប្បន្នដោយបញ្ចូលទាំងក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ បុគ្គលមានទំនាក់-ទំនងពិសេស ញាតិសម្ព័ន្ធ និងសាខាទាំងអស់របស់ក្រុមហ៊ុន។

៦- របាយការណ៍សវនកម្ម និងលិខិតផ្សេងៗដែលទទួលបានពីសវនករឯករាជ្យ ប្រសិនបើមាន។

៧- កិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ប្រសិនបើមាន។

៨- លិខិតបញ្ជាក់ពីក្រុមហ៊ុនពាក់ព័ន្ធដែលធានាកាតព្វកិច្ចបំណុលនៃក្រុមហ៊ុន និងបុគ្គលសម្ព័ន្ធទាំងអស់របស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងឯកសារពាក់ព័ន្ធ ប្រសិនបើមាន។

៩- របាយការណ៍ ឬព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **ន.ម.ក.**។

**ប្រការ៧ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវផ្តល់របាយការណ៍ជូន **ន.ម.ក.** តាមកាលបរិច្ឆេទដូចខាងក្រោម ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ក.**៖

១- របាយការណ៍ប្រចាំខែយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់។

២- របាយការណ៍ប្រចាំឆមាសយ៉ាងយូរ ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃបញ្ចប់ឆមាស។

៣- របាយការណ៍ប្រចាំឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់។

ក្នុងករណីដែលកាលបរិច្ឆេទចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះត្រូវចំថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាកការងារដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវផ្តល់របាយការណ៍នៅថ្ងៃធ្វើការបន្ទាប់។

## ជំពូកទី ៣
## កាតព្វកិច្ចជូនដំណឹង

**ប្រការ៨ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** អំពីការចាត់តាំងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និងក្រុមហ៊ុនអភិបាលមូលនិធិសម្រាប់មូលនិធិក្នុងគម្រោងវិនិយោគរួមនីមួយៗ ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យា ក្នុងរយៈពេល ៧(ប្រាំពីរ) ថ្ងៃបន្ទាប់ពីថ្ងៃចុះកិច្ចសន្យា។

**ប្រការ៩ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ក.** ក្នុងករណីមានការប្រែប្រួលនៃស្ថានភាពណាមួយដូចខាងក្រោម ដែលអាចជះឥទ្ធិពលជាសារវន្តដល់ក្រុមហ៊ុនក្នុងការប្រកបអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬអត្ថគាហកៈ៖

១- ស្ថានភាពគ្រប់គ្រងរបស់ក្រុមហ៊ុន។

២- រចនាសម្ព័ន្ធប្រាក់ចំណូលរបស់ក្រុមហ៊ុន។

៣- ទ្រព្យសកម្មរបស់ក្រុមហ៊ុន។

៤- ស្ថានភាពឥណទាន ឬបំណុលរបស់ក្រុមហ៊ុន។

៥- ស្ថានភាពវិនិយោគរបស់ក្រុមហ៊ុន។

៦- ការប្រែប្រួលផ្សេងទៀតដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការជូនដំណឹងត្រូវរួមបញ្ចូលទាំងការវាយតម្លៃអំពីឥទ្ធិពលនៃការប្រែប្រួលទាំងនោះលើក្រុមហ៊ុន និង អតិថិជនរបស់ក្រុមហ៊ុន ព្រមទាំងសកម្មភាព ឬវិធានការទាំងអស់ ដែលក្រុមហ៊ុនធ្វើឡើងដើម្បីគ្រប់គ្រងការប្រែប្រួលនោះ។

**ប្រការ១០ .-**

រាល់ការកែប្រែផែនការអាជីវកម្មរបស់ក្រុមហ៊ុន ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ភ.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃផ្លាស់ប្តូរ ដោយភ្ជាប់មកជាមួយនូវផែនការអាជីវកម្មថ្មី និងឯកសារបញ្ជាក់លើចំណុចដែលបានកែប្រែ។

**ប្រការ១១ .-**

ករណីក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើការទាមទារសំណងក្នុងក្របខណ្ឌកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ ឬធ្វើការផ្លាស់ប្តូរលក្ខខណ្ឌចម្បងនៃកិច្ចសន្យានោះ ដែលទាក់ទងនឹងអាជីវកម្មរបស់ក្រុមហ៊ុន ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ភ.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីមានការទាមទារសំណង ឬការផ្លាស់ប្តូរលក្ខខណ្ឌចម្បងនៃកិច្ចសន្យានោះ។

**ប្រការ១២ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ភ.** ប្រសិនបើក្រុមហ៊ុននោះ ក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ បុគ្គលមានទំនាក់ទំនងពិសេស ញាតិសម្ព័ន្ធ សាខា ការិយាល័យតំណាង ភាគហ៊ុនិក/សហកម្មសិទ្ធិករ សមាជិកគណៈកម្មធិការវិនិយោគ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ ភ្នាក់ងារគ្រប់គ្រងមូលនិធិ ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននោះ ដែលនៅក្នុងអំឡុងពេលបំពេញមុខងារ ស្ថិតក្នុងស្ថានភាពដូចខាងក្រោម៖

១- រងការស៊ើបអង្កេត រងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានពិរុទ្ធភាព ឬត្រូវបានផ្តន្ទាទោស ដោយសារការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅក្នុងយុត្តាធិការណាមួយ។

២- ជាប់បណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសកម្មភាពធុរកិច្ច ឬការអនុវត្តវិជ្ជាជីវៈក្នុងវិស័យមូលបត្រនៅក្នុងយុត្តាធិការណាមួយ។

៣- ទទួលរងពិន័យអន្តរការណ៍ ព្យួរឬដកហូតការចុះបញ្ជី អាជ្ញាបណ្ណឬការអនុញ្ញាត ឬត្រូវបានបដិសេធមិនឱ្យចុះបញ្ជី មិនផ្តល់អាជ្ញាបណ្ណឬមិនផ្តល់ការអនុញ្ញាត ដោយនិយ័តករ ស្ថាប័នស្វ័យនិយ័តករ ឬអង្គភាពវិជ្ជាជីវៈក្នុងយុត្តាធិការណាមួយ។

១០- ប្រើប្រាស់ឬកែប្រែវិធានប្រតិបត្តិការ។ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលមានបំណងកែប្រែវិធានប្រតិបត្តិការ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតកែប្រែមក **ន.ម.ក.** ដោយភ្ជាប់មកជាមួយនូវអត្ថបទ និងសេចក្ដីពន្យល់អំពីគម្រោងកែប្រែវិធានប្រតិបត្តិការនោះ។

១១- ប្រើប្រាស់ឬកែប្រែគោលការណ៍ស្គាល់អតិថិជន។ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលមានបំណងកែប្រែគោលការណ៍ស្គាល់អតិថិជន ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតកែប្រែមក **ន.ម.ក.** ដោយភ្ជាប់មកជាមួយនូវអត្ថបទ និងសេចក្ដីពន្យល់អំពីគម្រោងកែប្រែគោលការណ៍ស្គាល់អតិថិជននោះ។

១២- ប្រើប្រាស់ឬកែប្រែទម្រង់ពាក្យស្នើសុំបើកគណនី ទម្រង់វាយតម្លៃភាពសមស្របរបស់អតិថិជន ទម្រង់កិច្ចព្រមព្រៀងអតិថិជន ទម្រង់សេចក្ដីប្រកាសទទួលស្គាល់ហានិភ័យ និងទម្រង់កិច្ចព្រមព្រៀងប្រើប្រាស់សេវាអន្តរការីយកម្ម។ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលមានបំណងកែប្រែទម្រង់ទាំងនេះត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតកែប្រែមក **ន.ម.ក.** ដោយភ្ជាប់មកជាមួយនូវអត្ថបទ និងសេចក្ដីពន្យល់អំពីគម្រោងកែប្រែនោះ។

១៣- ផ្អាក ឬចាប់ផ្ដើមអាជីវកម្មឡើងវិញ ឬឈប់ធ្វើអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវផ្ដល់ជូន **ន.ម.ក.** នូវនីតិវិធី និងឯកសារពាក់ព័ន្ធនឹងការឈប់ធ្វើអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិក្នុងរយៈពេលយ៉ាងតិច ៦(ប្រាំមួយ) ខែ មុនថ្ងៃឈប់ធ្វើអាជីវកម្ម។ នីតិវិធី និងរយៈពេលនៃការអនុវត្តនីតិវិធីឈប់ធ្វើអាជីវកម្ម ត្រូវទទួលបានការអនុញ្ញាតពី **ន.ម.ក.**។ ក្នុងករណីការអនុវត្តនីតិវិធីនៃការឈប់ធ្វើអាជីវកម្ម ប្រើប្រាស់ពេលលើសពីរយៈពេលទទួលបានការអនុញ្ញាត **ន.ម.ក.** មានសិទ្ធិកំណត់រយៈពេលបន្ថែម។

១៤- បង្កើតបុគ្គលសម្ព័ន្ធ និងត្រូវរួមបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងបុគ្គលសម្ព័ន្ធនៅក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជាទៅក្នុងរាល់របាយការណ៍ដែលក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវផ្ដល់ជូន **ន.ម.ក.**។

១៥- ផ្ដល់ និងបញ្ចប់ការផ្ដល់មុខងារណាមួយទៅឱ្យតតិយជន។

១៦- ធ្វើអាជីវកម្មផ្សេងក្រៅពីអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលទទួលបានអាជ្ញាបណ្ណពី **ន.ម.ក.**។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវបំពេញតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយ **ន.ម.ក.** សម្រាប់ការស្នើសុំការអនុញ្ញាតដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការនេះ។

## ជំពូកទី ៥
## កម្រៃ និងសោហ៊ុយផ្សេងៗ

**ប្រការ២០ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជូន **ន.ម.ក.** ទៅតាមករណីដូចខាងក្រោម÷

**ប្រការ១៣ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលមានហេតុការណ៍ ឬមូលហេតុណាមួយដែលបណ្តាលឱ្យក្រុមហ៊ុនអាចឈានទៅរកការជម្រះបញ្ជី ការរំលាយក្រុមហ៊ុន ការផ្អាក ឬការឈប់ធ្វើអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

**ប្រការ១៤ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** អំពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុឬការឈប់សម្រាកលើសពីមួយខែ របស់បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិនិងភ្នាក់ងារគ្រប់គ្រងមូលនិធិ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអវត្តមានពីក្រុមហ៊ុនដោយគ្មានមូលហេតុរយៈពេល ៧ (ប្រាំពីរ) ថ្ងៃជាប់ៗគ្នា ឬទទួលបានលិខិតស្នើសុំឈប់សម្រាករបស់បុគ្គលនោះ។

**ប្រការ១៥ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** អំពីការឈប់សម្រាកមិនលើសពី ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ក្រៅពីថ្ងៃឈប់សម្រាកពីការងារដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ឱ្យបាន ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃឈប់សម្រាក។ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវធានាថាការឈប់សម្រាកនេះមិនប៉ះពាល់ដល់ផលប្រយោជន៍ជាសារវន្តរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងអត្ថគាហកៈ។

**ប្រការ១៦ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាបន្ទាន់មក **ន.ម.ក.** ក្នុងករណីមានចំណុចណាមួយដូចខាងក្រោម កើតឡើងចំពោះក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ ឬបុគ្គលមានទំនាក់ទំនងពិសេស នៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា÷

១- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការធ្វើអនុប្បទានអាជីវកម្មដោយផ្នែក ឬទាំងស្រុង។

២- ការហាមឃាត់ ឬការដាក់កម្រិតក្នុងការចេញមូលប្បទានប័ត្រ។

៣- ការចេញសេចក្តីសម្រេចរំលាយក្រុមហ៊ុន។

៤- ការចាប់ផ្តើមនៃនីតិវិធីណាមួយទាក់ទងនឹងនីតិវិធីនៃការក្ស័យធន។

៥- ករណីផ្សេងទៀតដែលតម្រូវដោយ **ន.ម.ក.**។

**ប្រការ១៧ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ក.** ប្រសិនបើក្រុមហ៊ុនគ្រប់គ្រងមូលនិធិពិនិត្យឃើញមានភាពមិនប្រក្រតីះ

១- ក្នុងការផ្តល់សេវាថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស រួមបញ្ចូលទាំងការបែងចែកប្រាក់ចំណេញ ភាគលាភ ការប្រាក់ ឬលាភការផ្សេងៗ ដល់អត្ថគាហកៈ។

២- ក្នុងការធ្វើប្រតិបត្តិការអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង របស់ក្រុមហ៊ុនចែក-ចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង។

៣- ក្នុងការធ្វើប្រតិបត្តិការផ្ទេរកម្មសិទ្ធិនៃឯកតាមូលនិធិ គណនាទ្រព្យសម្បត្តិបរធនវិនិយោគ វាយតម្លៃទ្រព្យសកម្មសុទ្ធ ដាក់តម្លៃឯកតាមូលនិធិ និងប្រតិបត្តិការពាក់ព័ន្ធផ្សេងទៀត របស់ក្រុមហ៊ុនអភិបាលមូលនិធិ។

**ប្រការ១៨ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ម.ក.** អំពីការដាក់ឱ្យប្រើប្រាស់ ឬផ្លាស់ប្តូរគេហទំព័រ បណ្តាញទំនាក់ទំនងសង្គម លេខទូរសព្ទ ឬអ៊ីមែលផ្លាល់របស់ក្រុមហ៊ុន ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីដាក់ឱ្យប្រើប្រាស់ ឬផ្លាស់ប្តូរ។

## ជំពូកទី ៤
## ភាគព្វកិច្ចស្នើសុំការអនុញ្ញាត

**ប្រការ១៩ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវស្នើសុំការអនុញ្ញាតពី **ន.ម.ក.** មុននឹងៈ

១- ផ្លាស់ប្តូរ ឬបញ្ចប់កិច្ចសន្យាជាមួយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសសម្រាប់មូលនិធិក្នុងគម្រោងវិនិយោគរួមណាមួយ។

២- ផ្លាស់ប្តូរ ឬបញ្ចប់កិច្ចសន្យាជាមួយក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងសម្រាប់មូលនិធិក្នុងគម្រោងវិនិយោគរួមណាមួយ។

៣- ផ្លាស់ប្តូរ ឬបញ្ចប់កិច្ចសន្យាជាមួយក្រុមហ៊ុនអភិបាលមូលនិធិសម្រាប់មូលនិធិក្នុងគម្រោងវិនិយោគរួមណាមួយ។

៤- ផ្លាស់ប្តូរភ្នាក់ងារគ្រប់គ្រងមូលនិធិពីផ្នែកអាជីវកម្មមួយទៅអាជីវកម្មមួយទៀតរបស់ក្រុមហ៊ុន។

៥- ផ្លាស់ប្តូរភ្នាក់ងារក្រោជហ្វាន់ឌីងពីផ្នែកសេវាកម្មមួយទៅផ្នែកសេវាកម្មមួយទៀតរបស់ក្រុមហ៊ុន។

៦- រំលាយក្រុមហ៊ុនបញ្ចូលគ្នា ទិញក្រុមហ៊ុន ឬផ្ទេរប្រតិបត្តិការអាជីវកម្ម។

៧- ផ្លាស់ប្តូរតំណាងនៃភាគហ៊ុនិកជានីតិបុគ្គល។

៨- ផ្លាស់ប្តូរ ឬកែប្រែផ្នែកឬមុខងារណាមួយនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ប្រតិបត្តិការអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

៩- ប្រើប្រាស់មូលធនភាគហ៊ុនិករបស់ខ្លួន ដើម្បីវិនិយោគក្នុងមូលនិធិក្នុងគម្រោងវិនិយោគរួមណាមួយដែលក្រុមហ៊ុនកំពុងគ្រប់គ្រង។

១- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០(ពីរលាន) រៀល ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី១, ចំណុចទី២, ចំណុចទី៣, ចំណុចទី៦, ចំណុចទី៨, ចំណុចទី១៣ ឬចំណុចទី១៤ នៃកថាខណ្ឌទី១ នៃប្រការ១៩ នៃប្រកាសនេះ។

២- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១.០០០.០០០(មួយលាន) រៀល ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី៩, ចំណុចទី១០, ចំណុចទី១១, ចំណុចទី១៥ ឬចំណុចទី១៦ នៃកថាខណ្ឌទី១ នៃប្រការ១៩ នៃប្រកាសនេះ។

៣- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២០០.០០០(ពីររយពាន់) រៀល ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី៤ ឬចំណុចទី៧ នៃកថាខណ្ឌទី១ នៃប្រការ១៩ នៃប្រកាសនេះ។

៤- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០(មួយរយពាន់) រៀល ក្នុងមួយទម្រង់ ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី១២ នៃកថាខណ្ឌទី១ នៃប្រការ១៩ នៃប្រកាសនេះ។

៥- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ៨០.០០០(ប៉ែតសិបពាន់) រៀល ចំពោះការស្នើសុំដូចមានចែងនៅក្នុងចំណុចទី៥ នៃកថាខណ្ឌទី១ នៃប្រការ១៩ នៃប្រកាសនេះ។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រការនេះ មិនត្រូវបានប្រគល់ជូនក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

**ប្រការ២១ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវបង់ប្រាក់ភាគទានជាប្រចាំខែចំនួន ០,៥ (សូន្យក្បៀសប្រាំ) ភាគរយនៃប្រាក់ចំណូលសរុបប្រចាំខែរបស់ក្រុមហ៊ុន ចូលក្នុងគណនីរបស់ **ន.ម.ក.** ក្នុងរយៈពេលយ៉ាងយូរត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ក.** សម្រាប់ទ្រទ្រង់កិច្ចដំណើរការរបស់ **ន.ម.ក.**។ **ន.ម.ក.** អាចធ្វើការផ្ទៀងផ្ទាត់ការបង់ភាគទាននេះជាមួយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន និងអាចតម្រូវឱ្យក្រុមហ៊ុនបង់ប្រាក់ភាគទានបន្ថែម ក្នុងករណីលទ្ធផលនៃការគណនាប្រាក់ភាគទានដែលក្រុមហ៊ុនត្រូវបង់ប្រចាំឆ្នាំមានចំនួនច្រើនជាងផលបូកនៃប្រាក់ភាគទានដែលក្រុមហ៊ុនបានបង់រួចប្រចាំខែ។

**ប្រការ២២ .-**

រាល់កម្រៃ សោហ៊ុយផ្សេងៗ រួមទាំងប្រាក់ពិន័យត្រូវបង់ចូលក្នុងគណនីរបស់ **ន.ម.ក.**។

## ជំពូកទី ៦
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ២៣ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវរៀបចំរាល់របាយការណ៍ និងព័ត៌មានអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ដើម្បីធានាឱ្យបាននូវភាពសុក្រឹត ច្បាស់លាស់ និងពេញលេញ។ ប្រសិនបើមានកំហុសឆ្គង ឬការខ្វះខាតណាមួយត្រូវបានរកឃើញ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ក.** និងត្រូវផ្តល់សារជាថ្មីនូវរបាយការណ៍ និងព័ត៌មានដែលកែតម្រូវរួច។

**ប្រការ២៤ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗតាមការតម្រូវរបស់ **ន.ម.ក.** ដើម្បីកំណត់ពីភាពត្រឹមត្រូវនៃក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្នុងការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ ឬសេចក្តីណែនាំរបស់ **ន.ម.ក.**។

**ប្រការ២៥ .-**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវរៀបចំរបាយការណ៍ និងផ្តល់ព័ត៌មានអនុលោមតាមប្រកាសនេះ ក្នុងទម្រង់ដែលកំណត់ដោយ **ន.ម.ក.**។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**ប្រការ២៦ .-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលប្រព្រឹត្តល្មើស ឬផ្តល់ព័ត៌មានខុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរនឹងប្រការ៤, ប្រការ៥, ប្រការ៦, ប្រការ៨, ប្រការ៩, ប្រការ១០, ប្រការ១១, ប្រការ១២, ប្រការ១៣, ប្រការ១៤, ប្រការ១៥, ប្រការ១៦, ប្រការ១៧, ប្រការ១៨, ប្រការ១៩, ប្រការ២៣, ប្រការ២៤, ប្រការ២៥ ឬមិនគោរពតាមការណែនាំ ការកំណត់ ឬការតម្រូវរបស់ **ន.ម.ក.** ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងនៅក្នុងប្រការ ២៧ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **ន.ម.ក.** ជាប្រាក់មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ ជូនដំណឹង ឬបង់ប្រាក់ភាគទានតាមរយៈពេល ឬកាលបរិច្ឆេទដូចមានកំណត់នៅក្នុងប្រការ៧ និងប្រការ២១ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ២៧ នៃប្រកាសនេះ និង/ឬទទួលពិន័យអន្តរការណ៍ពី **ន.ម.ក.** ជាប្រាក់ចំនួន ១.០០០.០០០(មួយលាន) រៀល ក្នុងមួយថ្ងៃ ចំពោះការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ ជូនដំណឹង ឬបង់ប្រាក់ភាគទានជូន **ន.ម.ក.**។

ក្នុងករណីមិនរាងចាល បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលពិន័យអន្តរការណ៍ទ្វេដង។

ក្នុងករណីការប្រព្រឹត្តល្មើសបានបង្កឱ្យមានព្យសនកម្ម បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលរងពិន័យអន្តរការណ៍ពី **ន.ម.ក.** និង/ឬជួសជុលសំណងព្យសនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មុននឹងចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី១, កថាខណ្ឌទី២, កថាខណ្ឌទី៣ ឬកថាខណ្ឌទី៤ នៃប្រការនេះ **ន.ម.ក.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

**ប្រការ២៧ .-**

ទណ្ឌកម្មរដ្ឋបាលមានដូចខាងក្រោម៖

១- ការព្រមាន ឬដាស់តឿន។

២- ការដឹកនាំកែតម្រង់។

៣- ការព្យួរ ឬបណ្តេញបុគ្គលិកជាន់ខ្ពស់ចេញពីមុខតំណែង។

៤- ការដាក់កម្រិតលើអាជ្ញាបណ្ណ។

៥- ការព្យួរអាជ្ញាបណ្ណ។

៦- ការដកហូតអាជ្ញាបណ្ណ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**ប្រការ២៨ .-**

**ន.ម.ក.** អាចចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

**ប្រការ២៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣០ .-**

អគ្គនាយកនៃ **ន.ម.ភ.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋានស្ថិតក្រោមចំណុះ **ន.ម.ភ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៨ កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ខែ ធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តមនិងលោកជំទាវអនុប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣០
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ